**នីតិវិធីប្ដឹងតវ៉ានៃមាតិកាទី ៦**

មាតិកាទី ៦ ហាមឃាត់លើការរើសអើងផ្អែកតាមពូជសាសន៍ ពណ៌សម្បុរ និងជាតិកំណើត។ ជាតិកំណើតសំដៅទៅលើប្រទេសជាក់លាក់ដែលបុគ្គលម្នាក់កើត ឬកន្លែងដែលឪពុកម្ដាយ ឬដូនតាបុគ្គលនោះកើត។ វាជាគោលនយោបាយរបស់ Foothill Transit ដែលគ្រប់បុគ្គលនឹងមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់សេវាកម្មរបស់ខ្លួន ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ជាតិកំណើត ឬសមត្ថភាពភាសាឡើយ។

បុគ្គលណាមួយដែលជឿថា ខ្លួនរងការរើសអើងផ្អែកតាមពូជសាសន៍ ពណ៌សម្បុរ ឬជាតិកំណើតដោយ Foothill Transit អាចដាក់បណ្ដឹងមាតិកាទី ៦ មួយ ហើយប្រគល់ពាក្យបណ្ដឹងតវ៉ានៃមាតិកាទី ៦ នេះ ជូន Foothill Transit បាន។ អ្នកប្ដឹងក៏អាចទូរស័ព្ទមកលេខ ១-៨០០-៧៤៣-៣៤៦៣ ដើម្បីដាក់បណ្ដឹងផងដែរ។ ពាក្យនេះអាចរកឃើញនៅលើវិបសាយ Foothill Transit http://www.foothilltransit.org/titlevi/ ឬ http://www.foothilltransit.org/library/ ឬក៏នៅតាមហាង ឬការិយាល័យរដ្ឋបាលណាមួយរបស់ Foothill Transit នៅ West Covina។ ដើម្បីស្នើសុំព័ត៌មានបន្ថែមអំពីកម្មវិធី Foothill Transit's Title VI Program សូមហៅទូរស័ព្ទលេខ៖ 1-800-743-3463

ពាក្យនេះអាចផ្ញើតាមប៉ុស្ដិ៍ប្រៃសណីយ៍ ឬប្រគល់មកការិយាល័យរដ្ឋបាល Foothill ឬហាង Transit ដែលមានទីតាំងនៅ៖

- ហាង និងការិយាល័យរដ្ឋបាល West Covina Transit៖ 100 S. Vincent Avenue 2nd Floor, West Covina, CA 91790
- ក្រុង Claremont៖ 200 W. 1st Street Claremont, CA 91711
- ក្រុងឧស្សាហកម្មនៅ Puente Hills Mall៖ 1600 Azusa Avenue Industry, CA 91748
- ស្ថានីយ El Monte៖ 3501 Santa Anita Avenue El Monte, CA 91731
- ក្រុង Pomona៖ 100 W. Commercial Street Pomona, CA 91768

អ្នកប្ដឹងក៏អាចប្រគល់បណ្ដឹងតវ៉ាទៅផ្នែករដ្ឋបាល Transit សហព័ន្ធដោយផ្ទាល់ផងដែរ៖

- ការិយាល័យ FTA នៃសិទ្ធិបុគ្គល (FTA Office of Civil Rights) 1200 New Jersey Avenue SE, Washington, DC 20590

Foothill Transit លើកទឹកចិត្តឱ្យអ្នកប្ដឹងដាក់បណ្ដឹងឱ្យបានឆាប់អស់ពីលទ្ធភាពបន្ទាប់ពីហេតុការណ៍ដែលចោទប្រកាន់នោះ ដើម្បីធានាឱ្យបាននូវការស៊ើបអង្កេតពេញលេញ។ លើសពីនេះ អ្នកប្ដឹងត្រូវបានលើកទឹកចិត្តឱ្យផ្ដល់ព័ត៌មានដែលស្មើទាំងអស់ដើម្បីធានាឱ្យបានការស៊ើបអង្កេតពេញលេញមួយ។ ជូនកាល ខ្សែវីដេអូពីការឡើងរថយន្តដឹកអ្នកដំណើរ Foothill Transit ត្រូវបានប្រើក្នុងដំណើរការស៊ើបអង្កេត។ ទោះយ៉ាងណាក៏ដោយ ខ្សែវីដេអូនេះត្រូវបានរក្សាទុកតែក្នុងចន្លោះពេលពី ៧ ទៅ ១៤ ថ្ងៃប៉ុណ្ណោះ បន្ទាប់ពីខណៈពេលមួយ អាស្រ័យទៅលើកាលៈទេសៈនានា។

ផ្អែកតាមគោលនយោបាយ Foothill Transit មតិមួយត្រូវបានស៊ើបអង្កេត ដោះស្រាយ និងបញ្ចប់ក្នុងរយៈពេលប្រាំថ្ងៃ បន្ទាប់ពីទទួលបានមតិនោះ ទៅតាមអ្វីដែលអាចធ្វើទៅបាន។ ក្នុងអំឡុងពេលនេះ Foothill Transit អាចទាក់ទងទៅអ្នកប្ដឹង ប្រសិនបើត្រូវការព័ត៌មានបន្ថែមដើម្បីដោះស្រាយករណីនេះ។ ប្រសិនបើអ្នកប្ដឹងមិនឆ្លើយតបវិញជាមួយនឹងព័ត៌មានដែលស្នើទេ Foothill Transit នឹងខិតខំអស់ពីលទ្ធភាពក្នុងការបញ្ចប់ការងារស៊ើបអង្កេតនេះជាមួយនឹងព័ត៌មានដែលបានផ្ដល់ជូន។ ម្យ៉ាងទៀត ប្រសិនបើអ្នកប្ដឹងដកបណ្ដឹងតវ៉ារបស់ខ្លួន ឬលែងចង់បន្តកិច្ចស៊ើបអង្កេតទៀត នោះករណីនេះអាចបញ្ចប់បាន។

បន្ទាប់ពីបណ្ដឹងត្រូវបានស៊ើបអង្កេត សមាជិកទទួលខុសត្រូវលើការងារស៊ើបអង្កេតនឹងព្យាយាមឆ្លើយតបនឹងអ្នកប្ដឹង។ ការឆ្លើយតបនេះនឹងចង្អុលបង្ហាញពីចរិកលក្ខណៈនៃការស៊ើបអង្កេត និងដំណោះស្រាយ។ ប្រសិនបើអ្នកប្ដឹងចង់ធ្វើបណ្ដឹងឧទ្ធរណ៍លើការសម្រេច គេអាចធ្វើបែបនោះបាន។ ជាថ្មីម្ដងទៀត Foothill Transit លើកទឹកចិត្តឱ្យអ្នកប្ដឹងដាក់បណ្ដឹងឧទ្ធរណ៍ឱ្យបានឆាប់អស់ពីលទ្ធភាពដើម្បីធានាដល់ការស៊ើបអង្កេត និងការឆ្លើយតបដ៏ពេញលេញមួយ។

# ពាក្យបណ្ដឹងតវ៉ា មាតិកាទី ៦

Foothill Transit សន្យានឹងផ្ដល់ការធានាថាគ្មានបុគ្គលណាមួយ ផ្អែកតាមពូជសាសន៍ ពណ៌សម្បុរ ឬជាតិកំណើត ត្រូវបានដកចេញពីការចូលរួម ឬត្រូវបានបដិសេធចោលពីផលប្រយោជន៍ទទួលបានសេវារបស់ខ្លួនឡើយ  ដូចដែលមានចែងក្នុងមាតិកាទី ៦ នៃក្រមច្បាប់សិទ្ធិបុគ្គល ឆ្នាំ ១៩៦៤ ដែលបានធ្វើវិសោធនកម្ម។ បណ្ដឹងតវ៉ាមាតិកាទី ៦ ត្រូវតែបំពេញចប់ក្នុងរយៈពេល ១៨០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលរងការរើសអើងដែលបានចោទប្រកាន់។

ព័ត៌មានខាងក្រោមគឺចាំបាច់សម្រាប់ជួយដល់យើងខ្ញុំក្នុងការដំណើរការបណ្ដឹងតវ៉ារបស់លោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការជំនួយណាមួយក្នុងការបំពេញពាក្យនេះ និងក្នុងការដាក់បណ្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរ សូមទាក់ទងអ្នកតំណាងមតិអតិថិជន (Customer Comment Representatives) របស់យើងខ្ញុំតាមលេខ ៨០០-៧៤៣-៣៤៦៣ ឬទៅកាន់*ហាង* Transit របស់យើងខ្ញុំណាមួយដោយផ្ទាល់។ ពាក្យដែលបំពេញចប់ត្រូវតែបញ្ជូនត្រឡប់មក Foothill Transit វិញដោយដាក់ថា៖ មាតិកាទី ៦ - មតិអតិថិជន 100 S. Vincent Ave., Suite 200, West Covina, CA 97190។

| | |
|---|---|
| ឈ្មោះលោកអ្នក៖ | លេខទូរស័ព្ទ៖ |
| អាស័យដ្ឋានផ្លូវ៖ | លេខទូរស័ព្ទផ្សេងទៀត៖ |
| ទីក្រុង រដ្ឋ & លេខកូដប្រៃសណីយ៍៖ | |
| អ្នករងការរើសអើង (ប្រសិនបើក្រៅពីអ្នកប្ដឹង)៖<br>ឈ្មោះ៖ | |
| អាស័យដ្ឋាន៖ | លេខទូរស័ព្ទ |
| ថ្ងៃកើតហេតុ៖ | រថយន្តដឹកអ្នកដំណើរ #/ផ្លូវ/ទីតាំង (បើមាន) |

តទៅទំព័រម្ខាងទៀត...

តើប្រកាខាងក្រោមណាមួយសាកសមបំផុតនឹងពិពណ៌នាពីមូលហេតុដែលនាំឱ្យកើតមានការរើសអើងដែលបានចោទប្រកាន់? (រើសយកមួយ)

☐ ពូជសាសន៍

☐ ពណ៌សម្បុរ

☐ ជាតិកំណើត (សមត្ថភាពភាសាអង់គ្លេសមានកម្រិត)

សូមពិពណ៌នាពីហេតុការរើសអើងដែលបានចោទប្រកាន់។ ចូរផ្តល់ឈ្មោះ និងងារនៃបណ្តាអ្នកតំណាង Foothill Transit ទាំងអស់ដែលពាក់ព័ន្ធ ប្រសិនបើមាន។ ចូរពន្យល់ពីអ្វីដែលបានកើតឡើង និងបណ្តាបុគ្គលដែលអ្នកជឿថាត្រូវទទួលខុសត្រូវ។ សូមប្រើសន្លឹកក្រដាសបន្ថែមនៃពាក្យនេះប្រសិនបើត្រូវការកន្លែងឆ្លើយបន្ថែមទៀត។

____________________________________________________________

តើលោកអ្នកមានដាក់បណ្តឹងតវ៉ាជាមួយភ្នាក់ងារសហព័ន្ធ រដ្ឋ ឬមូលដ្ឋានផ្សេងទៀតដែរទេ? មាន ☐ ទេ ☐

បើមាន សូមរាយឈ្មោះភ្នាក់ងារ និងព័ត៌មានទំនាក់ទំនងនៅខាងក្រោម៖

| | |
|---|---|
| ភ្នាក់ងារ៖ | ឈ្មោះទំនាក់ទំនង៖ |
| អាសយដ្ឋាន៖ | លេខទូរស័ព្ទ៖ |

*ខ្ញុំសូមអះអាងថា ខ្ញុំបានអានសេចក្តីចោទប្រកាន់ខាងលើ ហើយវាពិតជាក់ស្តែងមែនតាមតែអ្វីដែលខ្ញុំដឹង ឮ និងជឿ។*

**ហត្ថលេខា៖**__________________________________ **កាលបរិច្ឆេទ៖**____________________